ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កងទ័ពជើងគោក
យោធភូមិភាគទី៥

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលនៃកិច្ចប្រជុំវិសាមញ្ញ គណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ កម្ពុជា - ថៃ (RBC) ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ

កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការ ព្រំដែនថ្នាក់យោធភូមិភាគ កម្ពុជា-ថៃ (RBC) បានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ នៅខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ និងភាគីថៃធ្វើជាម្ចាស់ផ្ទះ។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥** និងជាសហប្រធាននៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។ គណៈប្រតិភូថៃដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក អាំម៉ារិទ្ធ ប៊ុនសុយ៉ា មេបញ្ជាការ កងទ័ពភូមិភាគទី១** និងជាសហប្រធាននៃកិច្ចប្រជុំវិសាមញ្ញរបស់ គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។

កិច្ចប្រជុំនេះមានគោលបំណងលើកកម្ពស់កិច្ចពិភាក្សា និងបង្កើនជំនឿទុកចិត្តសំដៅកាត់បន្ថយភាពតានតឹង រក្សាសន្តិភាពនៅតាមបណ្ដោយព្រំដែន ដោយប្រើប្រាស់យន្តការចាំបាច់ផ្សេងៗ ដើម្បីដោះស្រាយភាពផ្ទុយគ្នា ក្នុងស្មារតីនៃភាពជាអ្នកជិតខាងល្អ មិត្តភាព និងសាមគ្គីភាព។

ភាគីទាំងពីរបានប្ដេជ្ញាចិត្តក្នុងការអនុវត្តតាមលទ្ធផលនៃកិច្ចប្រជុំពិសេសរវាង **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ភូមិថាំ វីឆាយ៉ាឆៃ** នាយករដ្ឋមន្ត្រី**ស្ដីទីនៃព្រះរាជាណាចក្រថៃ** ដែលបានប្រព្រឹត្តទៅនៅទីក្រុងពូត្រាចាយ៉ា កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ដោយប្រទេសម៉ាឡេស៊ីធ្វើជាម្ចាស់ផ្ទះ និងសហការរៀបចំដោយសហរដ្ឋអាម៉េរិក ព្រមទាំងមានការចូលរួមយ៉ាងសកម្មពីសាធារណរដ្ឋប្រជាមានិតចិន។ ភាគីទាំងពីរក៏បានបញ្ជាក់សាជាថ្មីអំពីការប្ដេជ្ញាចិត្តក្នុងការអនុវត្តតាមលទ្ធផលនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) រវាងកម្ពុជា និងថៃ ដែលបានធ្វើឡើងនៅទីក្រុងគូឡាឡាំពួរ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។

បន្ថែមពីនេះ ភាគីទាំងពីរបានឯកភាពគ្នាក្នុងការរក្សាទំនាក់ទំនងជាប្រចាំរវាងបណ្ដាយោធភូមិភាគ និងតំបន់យោធា ព្រមទាំងបណ្ដាអង្គភាព នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ និងខិតខំដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងជៀសវាងការប៉ះទង្គិចគ្នា។ ភាគីទាំងពីរក៏បានបញ្ជាក់ពីសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងបន្ថែមទៀតនៅគ្រប់កម្រិត ដើម្បីកសាងជំនឿទុកចិត្ត និងលើកកម្ពស់ភាពជាអ្នកជិតខាងល្អ។ តាមរយៈការប្រាស្រ័យទាក់ទងគ្នានេះ ភាគីទាំងពីរបានសង្កត់ធ្ងន់ពីការវិវឌ្ឍជាវិជ្ជមាន និងវឌ្ឍនភាពដែលសម្រេចបាន ក្នុងការជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ជាមួយនឹងគោលបំណងរួមនៃការវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។

ភាគីកម្ពុជា និងថៃ បានឯកភាពគ្នាជាគោលការណ៍ក្នុងការបង្កើតក្រុមការងារសម្របសម្រួល (CG) ដើម្បីពង្រឹងទំនាក់ទំនងនៅគ្រប់កម្រិត រួមបញ្ចូលទាំងថ្នាក់មេបញ្ជាការ ក្រុមការងារទំនាក់ទំនងតាមព្រំ



យោធភូមិភាគទី៥ : លេខទូរសព្ទ(០១២), (០៩៨), (០៦០) ៣៧ ៦៣ ០៣ / តេឡេក្រាម ០១២ ៣៧ ៦៣ ០៣
អាសយដ្ឋាន:ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង Facebook Page:យោធភូមិភាគទី៥ www.facebook.com/millitaryregion5

ដែន កងកម្លាំងឈរជើងតាមតំបន់ព្រំដែន និងអង្គភាពប្រតិបត្តិការតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ក្នុងគោលបំណងដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងបញ្ចៀសការប៉ះទង្គិចគ្នា។ ភាគីទាំងពីរក៏បានពិចារណាអំពីលទ្ធភាពក្នុងការបង្កើតគណៈកម្មាធិការមូលដ្ឋានព្រំដែន (Township Border Committee-TBC) ដែលមានការចូលរួមពីស្ថាប័នរដ្ឋ និងឯកជន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ ខ្លឹមសារលម្អិតនឹងត្រូវយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។ ក្នុងអំឡុងពេលអន្តរកាល មុនការបង្កើតក្រុមការងារសម្របសម្រួល (CG) និងគណៈកម្មាធិការមូលដ្ឋានព្រំដែន (TBC) មេបញ្ជាការថ្នាក់មូលដ្ឋានរបស់ភាគីទាំងពីរនឹងជួបគ្នាជាទៀងរាល់សប្ដាហ៍ ឬតាមពេលវេលាសមស្រប ដើម្បីដោះស្រាយរាល់បញ្ហាដែលកើតមានឡើងនៅក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន។

ភាគីទាំងពីរបានបញ្ជាក់សាជាថ្មីនូវឆន្ទៈ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយគ្នាក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនរួមបញ្ចូលទាំងប្រតិបត្តិការមជ្ឈមណ្ឌលហៅទូរសព្ទ (ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការជួញដូរអាវុធ និងសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត ដោយធ្វើការស្វែងរកកិច្ចសហប្រតិបត្តិការច្បាស់លាស់ និងជាក់ស្ដែង តាមរយៈក្របខ័ណ្ឌដែលមានស្រាប់។ បញ្ហាទាំងនេះ ដែលស្ថិតក្រោមអាណត្តិរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) នឹងយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលគ្រោងនឹងធ្វើឡើងនាពេលឆាប់ៗខាងមុខនេះ ដូចដែលបានព្រមព្រៀងគ្នាដោយភាគីទាំងពីររួចហើយ។

ភាគីទាំងពីរបានបញ្ជាក់សាជាថ្មីនូវសារៈសំខាន់ក្នុងការដោះមីនមនុស្សធម៌ និងបានឯកភាពគ្នាបញ្ជូនបញ្ហានេះ ដែលស្ថិតក្រោមអាណត្តិរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ទៅកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលគ្រោងនឹងធ្វើឡើងនាពេលឆាប់ៗខាងមុខនេះ ដូចដែលបានព្រមព្រៀងគ្នាដោយភាគីទាំងពីររួចហើយ។

នៅក្នុងកិច្ចប្រជុំ ភាគីទាំងពីរក៏បានពិភាក្សាគ្នាក្នុងការស្វែងរកវិធានការជាក់ស្ដែង ដើម្បីដោះស្រាយបញ្ហានៃការវាយលួសបន្លានិងសំបកកង់ ព្រមទាំងការបង្កឧបសគ្គផ្សេងៗ ក្នុងគោលបំណងកាត់បន្ថយការលំបាកដែលសហគមន៍មូលដ្ឋានកំពុងប្រឈម សម្រួលដល់ការវិលត្រលប់របស់ប្រជាពលរដ្ឋប្រកបដោយសុវត្ថិភាពទៅកាន់លំនៅឋានវិញ និងកាត់បន្ថយផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគកម្ពុជា-ថៃ (RBC) បានបញ្ចប់ដោយភាគីកម្ពុជា និងថៃ បានបញ្ជាក់ពីការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការកសាងលើការវិវឌ្ឍជាវិជ្ជមាននេះ ការពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី និងការស្ដារប្រក្រតីភាពឡើងវិញនៅតាមតំបន់ព្រំដែន។ ភាគីទាំងពីរក៏បានឯកភាពគ្នាក្នុងការរៀបចំកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ (RBC) ក្នុងរយៈពេលមួយខែ ក្រោយកិច្ចប្រជុំវិសាមញ្ញនេះ ឬតាមពេលវេលាសមស្រប ដោយប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

ថ្ងៃសុក្រ ១៣រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

បន្ទាយមានជ័យ, ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥



យោធភូមិភាគទី៥ : លេខទូរសព្ទ(០១២), (០៩៨), (០៦០) ៣៧ ៦៣ ០៣ / តេឡេក្រាម ០១២ ៣៧ ៦៣ ០៣
អាសយដ្ឋាន:ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង Facebook Page:យោធភូមិភាគទី៥ www.facebook.com/millitaryregion5

**Press Release**

**Outcomes of the Cambodia-Thailand Extraordinary Regional Border Committee (RBC) Meeting on 22 August 2025, Sa Kaeo Province, the Kingdom of Thailand**

The Cambodia–Thailand Extraordinary Regional Border Committee (RBC) Meeting was held on 22 August 2025 in Sa Kaeo Province, the Kingdom of Thailand. The Cambodian delegation was led by Lieutenant General **Ek Sam Aun**, Commander of the 5th Military Region and Co-Chairman of the Extraordinary RBC Meeting. The Thai delegation was led by Lieutenant General **Amarit Boonsuya**, Commander of the 1st Army Area and Co-Chairman of the Extraordinary RBC Meeting.

The Meeting aimed at fostering discussion and increase confidence to de-escalate tension, maintain peace along the border using all necessary mechanisms to resolve differences in the spirit of good neighbourliness, friendship, and solidarity.

Both sides committed to implementing the outcomes of the Special Meeting between **Samdech Moha Borvor Thipadei Hun Manet**, Prime Minister of the Kingdom of Cambodia, and **His Excellency Phumtham Wechayachai**, Acting Prime Minister of the Kingdom of Thailand, held in Putrajaya on 28 July 2025, hosted by Malaysia and co-organized by the United States, with the active participation of the People's Republic of China. They also reaffirmed their commitment to implementing the outcomes of the Extraordinary General Border Committee (GBC) Meeting between Cambodia and Thailand, held in Kuala Lumpur on 7 August 2025.

In addition, the two sides agreed to maintain regular communications between all military regions and army areas and units along the Cambodia-Thailand border and strive to resolve all issues peacefully and avoid clashes. They underlined the importance of further intensifying the communication at all levels in order to build trust, and promote good neighbourliness. They also underscored the positive momentum and progress achieved through these engagements in advancing cooperation across all sectors, with the shared aim of returning to normalcy.

Both Cambodia and Thailand agreed in principle to establish a Coordinating Group (CG) to enhance communication at all levels, including between commanders, border liaison working groups, standing forces in the border areas, and operational units along the Cambodia-Thailand border, with the aim of resolving all issues peacefully and avoid clashes. They also considered the feasibility of establishing the Township Border Committee (TBC), which comprises of the state and private institutions, to strengthen cooperation in all sectors. The details will be discussed in the next RBC. In the interim, prior to the establishment of the CG and TBC, local task force commanders from both sides will meet weekly, or as appropriate, to resolve issues arising within their respective areas of responsibility.

Both sides reaffirmed their willingness to cooperate and collaborate with each other in combating and preventing transnational crimes, including call center operations (online scams), drug trafficking, human trafficking, weapons trafficking, and other cross-border criminal activities by exploring concrete and practical cooperation through existing frameworks. These issues, which

fall under the mandate of the GBC, should be addressed at the upcoming GBC Meeting, which is scheduled to take place soon, as agreed by both sides.

Both sides reaffirmed the importance of humanitarian demining and agreed to refer this issue, which falls under the mandate of the GBC, to the upcoming GBC Meeting, which is scheduled to take place soon, as agreed by both sides.

During the Meeting, both sides also discussed exploring practical measures to address the issues of barbed wire, tires, and other obstructions, with a view to alleviating the difficulties faced by local communities, facilitating the safe return of people to their homes, and mitigating the impacts on their livelihoods at the earliest possible time.

This Extraordinary RBC Meeting concluded with Cambodia and Thailand reaffirming their strong commitment to building on this positive momentum, further enhancing bilateral relations, and restoring normalcy along the border. The two sides also agreed to convene the next RBC Meeting within one month after this Extraordinary Meeting, or as appropriate, with Cambodia as the host.

*********